របាយការណ៍

# វគ្គបណ្តុះបណ្តាលរំលឹកអំពីការអនុវត្តន៍ នូវវិធីសាស្រ្តឆ្លើយតបរួមគ្នាក្នុងការបង្ការ ថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍,ជំងឺអេដស៍ និងសុខភាពបន្តពូជ  នៅស្រុកប្រតិបត្តិគីរីវង់ ខេត្តតាកែវ

គីរីវង់ ថ្ងៃទី ២៧-៣០ ខែ ធ្នូ ឆ្នាំ ២០១១



| រៀបចំដោយ | សហការណ៍ជាមួយ | ឧបត្ថម្ភថវិកាដោយ |
|---|---|---|
| NCHADS | NMCHC | ITM DGDC |

# វគ្គបណ្តុះបណ្តាលរំលឹកអំពីការអនុវត្តន៍
# នូវវិធីសាស្ត្រឆ្លើយតបរួមគ្នាក្នុងការបង្ការថែទាំព្យាបាល
# អ្នកផ្ទុកមេរោគអេដស៍,ជំងឺអេដស៍ និងសុខភាពបន្តពូជ នៅស្រុកប្រតិបត្តិគីរីវង់
# ខេត្តតាកែវ

១- **កាលបរិច្ឆេទ** : ពីថ្ងៃទី ២៧-៣០ ខែ ធ្នូ ឆ្នាំ ២០១១

២- **ទីកន្លែង** : សាលប្រជុំ នៃមន្ទីរពេទ្យបង្អែក គីរីវង់

៣- **ឧបត្ថម្ភដោយ** : ថវិកាមូលនិធិ ITM DGDC

៤- **រៀបចំដោយ** : រៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

**៥- គោលបំណងនៃសិក្ខាសាលា :**

-បច្ចុប្បន្នភាពការព្យាបាលថែទាំអ្នកជំងឺអេដស៍

-ពង្រឹង និងតាមដានស្ត្រីមានផ្ទៃពោះ និង កុមារប្រឈមមុខ

-ណែនាំពីការចុះបញ្ជី និង ការបំពេញរបាយការណ៍ដែលបានកែសំរួលថ្មី

-រំលឹកពីការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគ នៃការអនុវត្តនីវិធីសាស្ត្រឆ្លើយតបរួមគ្នាការថែទាំអ្នកជំងឺអេដស៍ និង សុខភាពបន្តពូជ នៅស្រុកប្រតិបត្តិគីរីវង់។

៦- **សមាសភាពចូលរួម: មានចំនួន ៧៤ នាក់** មកពី

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាមរោគ និងសើស្បែក ចំនួន ៥ រូប
- មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ចំនួន ២ រូប
- មន្ទីរសុខាភិបាលខេត្តតាកែវ ចំនួន ៥ នាក់
- មន្ត្រីសុខាភិបាលស្រុកប្រតិបត្តិគីរីវង់ ចំនួន ៥៩ រូប រួមមាន:
  - -មន្ត្រីស្រុកប្រតិបត្តិគីរីវង់ ចំនួន ៦ រូប
  - -មន្ត្រីមន្ទីរពេទ្យបង្អែកគីរីវង់ ចំនួន ១៣ រូប ( មានមន្ត្រីឆ្មប ចំនួន ០២ រូប)
  - -មណ្ឌលសុខភាព ជាន់ជុំ ចំនួន ០២ រូប ( មានមន្ត្រី ឆ្មប ចំនួន ០១ រូប)
  - -មណ្ឌលសុខភាព ភ្នំដិន ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព សោម ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព កំពែង ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព គោកព្រិច ចំនួន ០២ រូប ( មានមន្ត្រី ឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព អង្គប្រាសាទ ចំនួន ០២ រូប ( មានមន្ត្រី ឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព សន្លុង ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព ៨មុំ ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព អង្គខ្នុរ ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព គោកពោធិ ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព បូរីជលសារ ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព កំពង់ក្រសាង ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព ព្រៃយុទ្ធថ្កា ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព កំណប់ ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព ព្រៃមេលង ចំនួន ០២ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព ដូងខ្ពស់ ចំនួន ០៣ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព ក្រពុំឈូក ចំនួន ០៣ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព រមេញ ចំនួន ០៣ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព ព្រៃរំដេង ចំនួន ០៣ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-មណ្ឌលសុខភាព ជីខ្មារ ចំនួន ០៣ រូប ( មានមន្ត្រីឆ្មប ចំនួន ០១ រូប)

-អង្គការក្រៅរដ្ឋាភិបាល PC, RACHANA, AFD ចំនួន ៥ រូប

## ៧- សកម្មភាព:

វគ្គរំលឹកបានប្រព្រឹត្តិឡើងដោយ:

-កិច្ចស្វាគមន៍របស់លោកវេជ្ជ **ម៉ិច សំបូរ** ប្រធានស្រុកប្រតិបត្តិគីរីវង់

-មតិចូលរួមនិងចំណាប់អារម្មណ៏របស់លោកស្រី. **ទួន សុវណ្ណា** តំណាង NMCHC

-មតិចំណាប់អារម្មណ៏របស់លោកវេជ្ជ. **នុត ស៊ីណាត** អនុប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ

-មតិសំណេះសំណាល និងការប្រកាសបើកវគ្គរំលឹកដោយឯ.ឧ វេជ្ជបណ្ឌិត **មាន ឈីវ៉ុន** ទីប្រឹក្សាអមក្រសួងសុខាភិបាល និង ជាប្រធានមជ្ឈមណ្ឌលជាតិប្រយុទនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ ក្នុងឱកាសនោះ ឯ.ឧ វេជ្ជបណ្ឌិតបានសម្តែងនូវការកោតសរសើរចំពោះកិច្ចការដែលបានអនុវត្តន៍ការងារឆ្លើយ

តបរួមគ្នា និងសុខភាពបន្តពូជកន្លងមកដោយទទួលបានលទ្ធផលល្អ ធ្វើអោយអ្នកជំងឺមានសុខភាពល្អអាចប្រកបការងារបានកាត់បន្ថយអត្រាកុមារកំព្រារងគ្រោះដោយជំងឺអេដស៍បានទាន់ពេលវេលា ។

-ការបង្ហាញពីការណែនាំអោយគ្នាដោយលោកវេជ្ជ. **ទូច សារុន** មន្ត្រីផ្នែកថែទាំជំងឺអេដស៍

-ការបង្ហាញពីគោលបំណងដោយលោកវេជ្ជ. **សេង វុធី** អនុប្រធានផ្នែកថែទាំជំងឺអេដស៍ នៃ មជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ។

-ការបង្ហាញពីបច្ចុប្បន្នភាពសកម្មភាពឆ្លើយតមរួមគ្នាក្នុងការបង្ការ និងថែទាំព្យាបាលជំងឺអេដស៍ ជំងឺកាមរោគ និងលើកកំពស់សុខភាពបន្តពូជ ដោយលោកវេជ្ជ. **សរិត សុវណ្ណរិទ្ធ** ប្រធានផ្នែកថែទាំ ជំងឺអេដស៍ នៃ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។

-ចែកក្រុមពិភាក្សាតូច១ជា៨ក្រុម ហើយក្រុមតូចនិមួយ១ឡើងបង្ហាញពីសកម្មភាពដែលបានអនុវត្តន៏ ដោយឆ្លុះបញ្ចាំងពីភារៈកិច្ចដែលក្រុមនិមួយ១បានផ្តល់សេវាកន្លងមកជូនដល់ក្រុមគោលដៅលើប្រធានបទ រួមមានៈ ស្ត្រីមានផ្ទៃពោះ កុមារប្រឈមមុខ ការស្រាវជ្រាវរកស្ត្រីមានផ្ទៃពោះ ដោយមានសំណួរ និងចំលើយ ។

-ការបង្ហាញពីទំរង់ប័ណ្ណណាត់ជួបជាមួយអតិថិជន ប័ណ្ណវិភាគឈាម ប័ណ្ណបញ្ជូនអតិថិជន ដោយ លោក. **ទូច សារុន** និង លោក **ជា ចំណាន** មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ ដោយមានសំណួរ-ចំឡើយ និងមាន ការពិភាក្សា លំហាត់អនុវត្តន៏ ។

-ការបង្ហាញ និង ការអនុវត្តន៏លើការចុះបញ្ជីស្ត្រីមានផ្ទៃពោះមានពិនិត្យ និងការធ្វើតេស្តឈាម រកមេរោគអេដស៍ និងមេរោគស្វាយលើអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ ដោយលោកវេជ្ជ. **ងូវ បូរ៉ា** និង លោក **ស៊ុន សុខឡេង** មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ ដោយមានសំណួរ-ចំឡើយ និងមានការ ពិភាក្សា លំហាត់អនុវត្តន៏ ។

-ការបង្ហាញពីគោលការណ៏ណែនាំនៃបញ្ជីចុះឈ្មោះសំរាប់អិតថិជនទូទៅក្រៅពីស្ត្រីផ្ទៃពោះ មកធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយលោកស្រីវេជ្ជ **ទួន សុវណ្ណា** លោក **ស៊ុន សុខឡេង** ដោយមាន សំណួរ-ចំឡើយ ។

-ការប្រើប្រាស់ទំរង់របាយការណ៏ និង ប្រព័ន្ធបញ្ជូនសកម្មភាពសេវាឆ្លើយតបរួមគ្នាដោយលោកវេជ្ជ **ទូច សារុន** លោក **ស៊ុន សុខឡេង** ដោយមានសំណួរ-ចំឡើយ និងមាន ការពិភាក្សា ក្រុមតូច ។

-ការប្រមូលឈាមមកវិភាគ ការរក្សាឈាមទុក ការបញ្ជូនឈាមក្នុងប្រព័ន្ធ សកម្មភាពសេវាឆ្លើយ តបរួមគ្នា ដោយលោកវេជ្ជ **ទូច សារុន** លោក **ទេព សុធី** និង លោកអ្នកបច្ចេកទេសមន្ទីរពិសោធន៏ និងមន្ត្រីមន្ទីរពេទ្យបង្អែក ដោយមាន សំណួរ-ចំឡើយ និងមានការពិភាក្សាក្រុមតូច ។

- ការពិភាក្សាទូទៅរួមក្រុមធំ

- វាយតំលៃវគ្គកិច្ចប្រជុំ និង ប្រកាសបិទវគ្គ ដោយលោកវេជ្ជ. **មាន ឈីវុន** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ បានធ្វើការដោះស្រាយរាល់សំណួរ និង បញ្ហាផ្សេងៗដែលបានលើកឡើង ដោយស្រុកប្រតិបត្តិ មណ្ឌលសុខភាព និង អង្គការមួយចំនួន និងបញ្ហាមួយចំនួនដែលមិនអាចដោះស្រាយ ។

## ៨- លទ្ធផលៈ

- មានគំរូរបាយការណ៏មួយដែលមានលក្ខណៈ ស្តង់ដារូម
- សិក្ខាកាមយល់ដឹងពីការបំពេញទំរង់របាយការណ៏ការឆ្លើយតបរួមគ្នាពីជំងឺអេដស៏
- បានធ្វើការពិភាក្សាជាលក្ខណៈក្រុមតូច/ក្រុមធំ លើការបំពេញទំរង់របាយការណ៏
- បានឯកភាពបន្តសកម្មភាពអនុវត្តន៏ការឆ្លើយតបរួមគ្នាដែលមានស្រាប់ទៀត
- ធ្វើការយ៉ាងជិតស្និតល្អរវាងមន្ត្រីទាំងអស់ និងមានកិរិតបេជ្ញាចិត្តខ្ពស់ ។

## ៩- សំណូមពរ

- សូម NCHADS ជួយប្រាក់ឧបត្ថម្ភបន្ថែម
- សូមអោយការប្រជុំទៀងទាត់ ដើម្បីដោះស្រាយ បញ្ហា និងស្វែងរកការគាំទ្រពីថ្នាក់លើ

វគ្គរំលឹកនេះបានបញ្ចប់នូវល្ងាចថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១ វេលាម៉ោង ១៧:៣០ នាទីក្រោមអធិបតីភាពប្រកាសបិទវគ្គដោយឯ.ឧ វេជ្ជ. **មាន ឈីវុន** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង ជំងឺអេដស៍ សើស្បែក និងកាមរោគ និង ជាទីប្រឹក្សាអមក្រសួងសុខាភិបាល មានមតិសំណេះសំណាលផ្តាំផ្ញើនឹងការប្រកាសបិទកម្មវិធី ។

ថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១២

បានឃើញ និងឯកភាព
ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹង
ជំងឺអេដស៍ សើស្បែក និងកាមរោគ

វេជ្ជ មាន_ឈីវុន

អ្នកធ្វើរបាយការណ៏

វេជ្ជ. សេង វុធី